# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៥ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ១៥០ សសរ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១.-**

កែសម្រួលសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **មៀច សុផាន់ណា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- ឯកឧត្តម | **ប៉ុក ម៉ាន់នី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៣- ឯកឧត្តម | **គីម ជាតិ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៤- ឯកឧត្តម | **សុខ សារេត** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | ជាអនុប្រធាន |



www.pheakdeylaw.com

៥-ឯកឧត្តម នាយឧត្តមសេនីយ៍ **កង សុខន** អគ្គស្នងការរងនគរបាលជាតិ ជាអនុប្រធាន

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សរ សិទ្ធិ** ទីប្រឹក្សាក្រសួងមហាផ្ទៃ ជាសមាជិកអចិន្ត្រៃយ៍

៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃុន សំបូរ** អគ្គនាយករងអន្តោប្រវេសន៍ ជាសមាជិក

៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ិន សុផានី** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

៩-ឯកឧត្តម **ឯមយិន ទេរ:** អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

១០-ឯកឧត្តម **គឹម មាសសុខសីហា** អគ្គនាយករងកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក

១១-លោកទន្តបណ្ឌិត **ទឿន បូរារ័ត្នន៍** អគ្គនាយករងបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល ជាសមាជិក

១២-លោក **ចិន សេងហ៊ាង** អនុប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាសមាជិក

១៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាន់ ម៉ាន់ឡឿន** ប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ជាសមាជិក

១៤-លោក ឧត្តមសេនីយ៍ទោ **លីម សុផាណារិទ្ធិ** ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំង ផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ ដល់សុខភាព និងសុវត្ថិភាពសង្គម ជាសមាជិក

១៥-លោក ឧត្តមសេនីយ៍ទោ **និត្យ គឹមអ៊ីន** អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ជាសមាជិក

១៦-លោក ឱសថការី **ហ្វូត សេងថុង** អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ក្រសួងសុខាភិបាល ជាសមាជិក

១៧-លោក ឧត្តមសេនីយ៍ត្រី **ឡុង ស្រេង** អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ជាសមាជិក

១៨-លោក វរសេនីយ៍ឯក **ស្វួន ណារ៉ា** អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ជាសមាជិក

១៩-លោក វរសេនីយ៍ឯក **សុខ សុមនោ** ជំនួយការក្រសួងមហាផ្ទៃ ជាសមាជិក



www.pheakdeylaw.com

**ប្រការ ២.-**

តួនាទី ភារកិច្ច របស់សមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តតាម សេចក្តីសម្រេចលេខ ១៥០ សសរ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com